# ការទប់ស្កាត់អំពើហិង្សា ទាក់ទងនឹងយេនឌ័រ និង ការបៀតបៀន នៅកន្លែងធ្វើការ

ឯកសារអនុសាសន៍
ស្តីពីនិរន្តរភាព

# Prevention of Gender-Based Violence and Harassment at the Workplace

Sustainable
Recommendation
Paper





កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

FABRIC Cambodia

RESPONSIBLE BUSINESS HUB CAMBODIA
RBH NETWORK

EUROCHAM CAMBODIA

care

TAFTAC
Textile, Apparel, Footwear & Travel Goods Association in Cambodia

# សេចក្តីសង្ខេប

ឯកសារអនុសាសន៍ស្តីពីនិរន្តរភាព ក្រោមប្រធានបទ **«ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន នៅកន្លែងធ្វើការ»** ថ្លែងពីបញ្ហាសំខាន់ៗនៃអំពើហិង្សា និងការបៀតបៀនទាក់ទងនឹងយេនឌ័រ នៅក្នុងឧស្សាហកម្មវាយនភណ្ឌនិងកាត់ដេរនៅកម្ពុជា។ ឯកសារនេះ ផ្តល់នូវយុទ្ធសាស្ត្រទូលំទូលាយ និងការណែនាំជាអនុសាសន៍សម្រាប់ភាគីពាក់ព័ន្ធផ្សេងៗ រួមទាំងរាជរដ្ឋាភិបាល រោងចក្រ អ្នកបញ្ជារទិញ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀនប្រកបដោយប្រសិទ្ធភាព។

តាមរយៈកិច្ចពិភាក្សាពហុភាគីពាក់ព័ន្ធ ចន្លោះខ្វះខាតសំខាន់ៗមួយចំនួនត្រូវបានរកឃើញ ដែលពាក់ព័ន្ធទៅនឹងការយល់ដឹង ការរាយការណ៍ និងយន្តការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន។ ការរកឃើញសំខាន់ៗទាំងនេះរួមមាន៖

- **កង្វះការយល់ដឹង និងការទប់ស្កាត់៖** មានការខ្វះខាតការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន ក្នុងចំណោមកម្មករកម្មការនី និងផ្នែកគ្រប់គ្រង ដែលនាំឱ្យមានចំនួនរាយការណ៍ករណីទាប និងវិធានការទប់ស្កាត់មិនមានប្រសិទ្ធភាព។ បទដ្ឋានផ្នត់គំនិតសង្គម និងការស្តីបន្ទោសជនរងគ្រោះ ក៏រួមចំណែកដល់អត្រារាយការណ៍ករណីទាប និងការគាំទ្រមិនគ្រប់គ្រាន់សម្រាប់ជនរងគ្រោះផងដែរ។
- **យន្តការ និងប្រព័ន្ធគ្មានប្រសិទ្ធភាព៖** យន្តការទប់ស្កាត់ និងការឆ្លើយតបដែលមានស្រាប់នោះ មិនមានភាពគ្រប់គ្រាន់ កង្វះទំនុកចិត្ត និងការឆ្លើយតបយឺតយ៉ាវ ដែលរារាំងដល់ការរាយការណ៍ករណី និងលុបបំបាត់ការជឿទុកចិត្តលើប្រព័ន្ធរាយការណ៍ និងឆ្លើយតបនោះ។ ការចាត់ទុកអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន ជារឿងធម្មតា គួបផ្សំនឹងការមិនអនុវត្តគោលការណ៍ «គ្មានការអត់ឱន លើការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន» នៅកន្លែងធ្វើការ នៅតែបន្តកើតមាន។ លើសពីនេះទៀត រោងចក្រនៅតែមានការស្ទាក់ស្ទើរក្នុងការបង្ហាញទិន្នន័យអំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន ដោយខ្លាចមានផលវិបាកពីអ្នកបញ្ជារទិញ។
- **ការផ្តល់សេវាគាំទ្រមិនគ្រប់គ្រាន់៖** ជនរងគ្រោះខ្វះព័ត៌មានអំពីសេវាគាំទ្រនានាដែលមាននៅក្នុងរោងចក្រ និងក្នុងសហគមន៍របស់ពួកគេ។ ជារឿយៗ ពួកគេមិនអាចទទួលបានជំនួយផ្នែកច្បាប់ ឬផ្លូវចិត្ត ដោយសារសេវាមានមិនគ្រប់គ្រាន់ និងមានតម្លៃថ្លៃ។
- **គោលនយោបាយ និងការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព៖** ច្បាប់ជាតិ គោលនយោបាយ និងនីតិវិធីមាននៅហ្នឹងកន្លែង ប៉ុន្តែមានកង្វះខាតនូវការអនុវត្តដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន នៅក្នុងវិស័យឧស្សាហកម្មវាយនភណ្ឌនិងកាត់ដេរនៅកម្ពុជា។

## សកម្មភាពដែលបានណែនាំ

ឯកសារនេះរួមបញ្ចូលនូវអនុសាសន៍ដែលត្រូវបានធ្វើឡើងនៅក្នុងកម្មវិធីកិច្ចពិភាក្សារវាងវិស័យសាធារណៈ និងវិស័យឯកជន និងកម្មវិធីពិគ្រោះយោបល់ភាគីពាក់ព័ន្ធអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន នៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ឯកសារនេះក៏ណែនាំនូវសកម្មភាពជាក់ស្តែងដែលត្រូវធ្វើសម្រាប់ក្រុមភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីអនុវត្តអនុសាសន៍ និងឆ្ពោះទៅរកគំនិតផ្តួចផ្តើមថ្មីៗនៃកិច្ចសហប្រតិបត្តិការពហុភាគី។ ធាតុសំខាន់ៗមានរៀបរាប់នៅខាងក្រោម៖

### ១. សកម្មភាពរបស់រាជរដ្ឋាភិបាល៖

- កែលម្អច្បាប់ និងយន្តការអនុវត្ត ធានាតម្លាភាព និងគណនេយ្យភាព។
- អង្គការសង្គមស៊ីវិលជាច្រើន គាំទ្រដល់ការផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ (ILO) លេខ ១៩០ ដើម្បីពង្រឹងការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន នៅគ្រប់វិស័យ (ជាជំហរមួយដែលមិនទទួលបានការគាំទ្រពី TAFTAC ឡើយ)។
- បង្កើនការវិនិយោគក្នុងយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈនិងផ្តល់នូវសេវាគាំទ្រនានាអោយបានទូលំទូលាយ ពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន រួមទាំងការគាំទ្រផ្នែកច្បាប់ សុខភាព និងផ្លូវចិត្ត។

### ២. ការគាំទ្រដែលរោងចក្រគួរធ្វើ៖

- សហការជាមួយក្រុមភាគីពាក់ព័ន្ធ ដើម្បីបង្កើនវិធានការទប់ស្កាត់ និងឆ្លើយតប ដែលលើសពីការរាយការណ៍ ដោយធានាបាននូវលទ្ធភាពទទួលបានសេវាគាំទ្រទាន់ពេលវេលា សម្រាប់ជនរងគ្រោះ។
- អ្នកបញ្ជារទិញគួរតែវិនិយោគ និងគាំទ្រដល់រោងចក្រ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព នូវគោលនយោបាយស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន ដោយរួមបញ្ចូលការត្រួតពិនិត្យភាពត្រឹមត្រូវ និងកិច្ចព្រមព្រៀងចរចារួមគ្នា ទៅក្នុងដំណើរការអនុលោមភាព។
- សហការជាមួយក្រុមភាគីពាក់ព័ន្ធ អ្នកបញ្ជារទិញ និងតំណាងកម្មករកម្មការនី ដើម្បីបង្កើត និងធានាដំណើរការអនុវត្តយន្តការបណ្តឹងសារទុក្ខ ដើម្បីអាចដោះស្រាយបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន ទាន់ពេលវេលា និងមានប្រសិទ្ធភាព។

### ៣. ការគាំទ្រដែលអ្នកបញ្ជារទិញគួរធ្វើ៖

- ជំរុញកិច្ចសហការរវាងដៃគូធុរកិច្ច ទីភ្នាក់ងាររាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងគណនេយ្យភាពក្នុងវិស័យឧស្សាហកម្មវាយនភណ្ឌនិងកាត់ដេរនៅកម្ពុជា។
- ប្រើប្រាស់វេទិកាដូចជាមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយទំនួលខុសត្រូវ (RBH) ដើម្បីសម្របសម្រួល និងអនុវត្តយុទ្ធសាស្ត្រស្របគ្នា។

## ដំណើរឆ្ពោះទៅមុខ

ការទទួលខុសត្រូវរួមគ្នារវាងភាគីពាក់ព័ន្ធក្នុងវិស័យសាធារណៈ និងវិស័យឯកជន គឺចាំបាច់សម្រាប់ធានានិរន្តរភាពនៃឧស្សាហកម្មវាយនភណ្ឌនិងកាត់ដេនៅកម្ពុជា។ ទីភ្នាក់ងាររាជរដ្ឋាភិបាលត្រូវតែនាំមុខក្នុងការធានាការអនុវត្តច្បាប់ និងគោលនយោបាយ។ អ្នកផ្គត់ផ្គង់ អ្នកលក់ និងអ្នកបញ្ជារទិញ អាចគាំទ្រកិច្ចខិតខំប្រឹងប្រែងទាំងនេះ តាមរយៈការបង្កើនការវិនិយោគ និងគណនេយ្យភាព។ អង្គការសង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រទាំងគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល និងវិស័យឯកជន។ ការបន្តកិច្ចសហប្រតិបត្តិការ និងកិច្ចពិភាក្សាមានសារៈសំខាន់សម្រាប់ការជំរុញរបៀបវារៈស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន។ វេទិកាដូចជាមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយទំនួលខុសត្រូវ (RBH) និងគំនិតផ្តួចផ្តើមដោយ GIZ-FABRIC នឹងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ២០២២-២០២៧ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលទីបំផុតនឹងជំរុញបរិយាកាសការងារដែលគ្មានអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន។

ដើម្បីរក្សាការទប់ស្កាត់និងការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន ប្រកបដោយប្រសិទ្ធភាពនៅក្នុងឧស្សាហកម្មវាយនភណ្ឌរកាត់ដេររបស់កម្ពុជាការសិក្សានេះសង្កត់ធ្ងន់ទៅលើតម្រូវការសម្រាប់ការវិនិយោគបន្ត ការពង្រឹងយន្តការអនុវត្ត និងកិច្ចសហប្រតិបត្តិការពហុភាគី។

# Executive Summary

The Sustainability Recommendation Paper on the **Prevention of Gender-Based Violence and Harassment (GBVH) at the Workplace** addresses important issues of GBVH in the Cambodian textile industry. The document entails comprehensive strategies and recommended actions for various stakeholders, including the government, factories, buyers, civil society organisations, and development partners to combat GBVH effectively.

Through multi-stakeholder dialogues, several significant gaps in awareness, reporting, and mechanisms for preventing and responding to GBVH in the textile industry have been identified. These major findings include:

- **Lack of Awareness and Prevention:** There is a lack of understanding of GBVH among workers and management, leading to underreporting and ineffective prevention measures. Social norms and victim-blaming also contribute to low reporting rates and inadequate support for survivors.
- **Ineffective Mechanisms and Systems:** Existing prevention and response mechanisms are often inadequate, with low trust and delayed responses discouraging reporting and eroding trust in the system. Normalisation of GBVH is also common, coupled with no implementation of zero-tolerance policies at the workplace. In addition, suppliers are hesitant to disclose any GBVH cases in fear of consequences from buyers.
- **Inadequate Comprehensive Services:** Survivors lack information about available services at the factories and in their communities. Often, they could not access legal or psychological support due to inadequate and expensive services.
- **Ineffective Policies and Laws Enforcement:** The national laws, policies, and procedures are in place, but they lack the enforcement to prevent and respond to GBVH in the garment sector.

## Recommended Actions

The paper consolidates recommendations that were made in public-private dialogue events and stakeholder consultations on GBVH in Cambodia over the past years. It also suggests concrete actions to be taken per main stakeholder group to implement the recommendations and move towards new initiatives of multi-stakeholder cooperation. The main ones are listed here:

### 1. Government Actions:

- Improve laws and enforcement mechanisms, ensuring transparency and accountability.
- Various civil society actors promote the ratification of ILO Convention No. 190 to strengthen GBVH prevention and response across sectors (a position which is not supported by TAFTAC).
- Increase investment in public awareness campaigns and comprehensive GBVH services, including legal, health, and psychological support.

### 2. Support to Factories:

- Collaborate with stakeholders to enhance preventive and responsive measures beyond mere reporting, ensuring timely access to services for survivors.
- Buyers should invest in and support suppliers to implement effective GBVH policies, integrating due diligence and collective bargaining agreements into compliance processes.
- Collaborate with stakeholders, buyers, and workers representatives to establish and implement a functional grievance mechanism at the workplace that can address GBVH in a timely and effective manner.

### 3. Support to Buyers:

- Foster collaboration among business partners, government agencies, and civil society to support sustainable development and accountability in the textile sector.
- Utilize platforms like the Responsible Business Hub (RBH) to coordinate and implement aligned strategies.

## The Way Forward

Shared accountability between public and private stakeholders is necessary for the sustainability of the textile industry in Cambodia. Government agencies must take the lead in enforcing laws and policies. Suppliers, vendors, and buyers can support these efforts through increased investment and accountability. Civil society organisations play a crucial role in supporting both government and private sector initiatives. Continued cooperation and dialogue are essential for advancing the GBVH agenda. Platforms like the Responsible Business Hub (RBH) and initiatives by GIZ-FABRIC will support the implementation of the Cambodian Government‘s Garment Footwear and Travel Goods Sector Development Strategy 2022–2027, ultimately fostering a GBVH-free workplace environment.

To maintain effective GBVH prevention and response in Cambodia‘s textile industry, the study emphasizes the need for continued investment, enhanced enforcement mechanisms, and multi-stakeholder collaboration.



**Published by:**
Deutsche Gesellschaft für
Internationale Zusammenarbeit (GIZ) GmbH

Registered offices
Bonn and Eschborn, Germany

GIZ Office Phnom Penh
Oval Office Tower, 10F Building No. 1 Street 360, Boeung Keng Kang 1
Phnom Penh, Cambodia
T +855 23 860 110
E giz-kambodscha@giz.de
I www.giz.de/cambodia

**Project description:**
FABRIC Cambodia

**Author/Responsible/Editor:**
CARE Cambodia , Street 352, Boeng Keng Kang Muoy, Phnom Penh

**Design/layout:**
FLMH Labor für Politik und Kommunikation GmbH, Berlin

**Photo credits/sources:**
GIZ/ Roman König

On behalf of
German Federal Ministry for Economic Cooperation and Development (BMZ)

Phnom Penh, 2024